**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**
**តុលាការព្រហ្មទណ្ឌ**

សំណុំរឿងព្រហ្មទណ្ឌលេខ ២៦០
ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣

**សាលក្រមលេខ ០៧-ឈ-/១១៨**
ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៤

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្ត សៀមរាប

| | | |
|---|---|---|
| កាលបរិច្ឆេទនៃសវនាការជាសាធារណៈ | ៖ | ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤ |
| សាលសវនាការ និងពេលវេលា | ៖ | សាល ក២ វេលាម៉ោង ៩:៣០ |
| កាលបរិច្ឆេទនៃការប្រកាសសាលក្រម | ៖ | ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៤ |
| សាលសវនាការ និងពេលវេលា | ៖ | សាល ក២ វេលាម៉ោង ៩:១០ |

**ក្រោមសមាសភាពជំនុំជម្រះ**

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ឋានៈ ចៅក្រមសាលាដំបូង

**តំណាងអយ្យការ**

លោក [redacted] ឋានៈ ព្រះរាជអាជ្ញារង អមសាលាដំបូង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ឋានៈ ក្រឡាបញ្ជីសាលាដំបូង

**ដើម្បីធ្វើការពិភាក្សាដេញដោលលើ**

**ជនជាប់ចោទ**

១- ឈ្មោះ [redacted] **លីហ៊ាង** ភេទស្រី អាយុ៥៧ឆ្នាំ ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ កើតនៅ [redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូ [redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ ថ្នាក់ទី១២ មុខរបរ នៅផ្ទះ ប្តីឈ្មោះ [redacted] **ពិសិដ្ឋជាវិត** មានកូន២នាក់ ឪពុកឈ្មោះ [redacted] ហ៊ួង "ស្លាប់" ម្តាយឈ្មោះ [redacted] គីមហ៊ន់ "ស្លាប់" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន គ្មាន (គេចខ្លួន)

*ដីកាបង្គាប់ឱ្យចូលខ្លួនលេខ ២៦៤៦ ពស.ព្រស/ឱ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣*

២- ឈ្មោះ [redacted] **ពិសិដ្ឋជាវិត** ភេទប្រុស អាយុ៥៥ឆ្នាំ កើតឆ្នាំ១៩៦៨ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ប្រពន្ធឈ្មោះ [redacted] លីហ៊ាង មានកូន២នាក់(គេចខ្លួន)

*ដីកាបង្គាប់ឱ្យចូលខ្លួនលេខ ២៦៤៧ ពស.ព្រស/ឱ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣*

ជនទាំងនេះត្រូវបានបញ្ជូនមកជំនុំជម្រះពីបទ **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍**



Scanned with CamScanner

**អាចជួញដូរបាន** ប្រព្រឹត្តនៅភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២៣១** នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

- លោក [redacted] ជាមេធាវីការពារសិទ្ធិ (វត្តមាន)

**ដើមបណ្តឹងរដ្ឋប្បវេណី**

**គ្រឹះស្ថាន វ៉ាយ ស៊ី ភី ម៉ាយក្រូហ្វាយនែន ម.ក**

អាសយដ្ឋាននៅផ្ទះលេខ 73A ផ្លូវ 118 សង្កាត់ទឹកល្អក់ ខណ្ឌទួលគោក រាជធានីភ្នំពេញ

តំណាងដោយលោក [redacted] **សែ** ជានាយកប្រតិបត្តិការ

- លោក [redacted] ជាមេធាវីការពារសិទ្ធិ (អវត្តមាន)
- លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិ (វត្តមាន)
- លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិ (វត្តមាន)

**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ **៦៦១ អយក** ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប ។

**បានឃើញ** ដីកាដំណោះស្រាយ(បញ្ជូនទៅជំនុំជម្រះ)លេខ **៥១៧៥ ពស.ព្រស/ឱ** ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប ។

**បានឃើញ** ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ **៩១៨ ដកចត/២៣** ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។

**បានឃើញ** ដីកាកំណត់កាលបរិច្ឆេទសវនាការលេខ **២៥ ដកកសក/ក** ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២៤ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។

**អង្គហេតុដែលប្តឹងមកតុលាការ**

កាលពីអំឡុងឆ្នាំ២០១៩ ឈ្មោះ [redacted] **ស៊ាវ** ឈ្មោះ [redacted] **ប៊ុនធា** និងឈ្មោះ [redacted] **លក្ខស៊ី** បានខ្ចីប្រាក់ពីគ្រឹះស្ថាន **វ៉ាយ ស៊ី ភី** ម៉ាយក្រូហ្វាយនែន ម.ក ហើយឈ្មោះ [redacted] **ពិសិដ្ឋដាវិត** និងប្រពន្ធឈ្មោះ [redacted] **លីហ៊ាង** ជាអ្នកធានា បានចេញមូលប្បទានបត្រនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២០ ចំនួន ៤សន្លឹក របស់ **ធនាគារ វឌ្ឍនៈអាស៊ីចំកាត់(ABA Bank)** មានលេខ **496341** មានទឹកប្រាក់ចំនួន **20.000**(ពីរម៉ឺន)ដុល្លារអាមេរិក, លេខ **496343** មានទឹកប្រាក់ចំនួន **10.000**(មួយម៉ឺន)ដុល្លារអាមេរិក, លេខ **496342** មានទឹកប្រាក់ចំនួន **20.000**(ពីរម៉ឺន)ដុល្លារអាមេរិក និងលេខ **496344** មានទឹកប្រាក់ចំនួន **10.000**(មួយម៉ឺន)ដុល្លារអាមេរិក សរុបជាទឹកប្រាក់ចំនួន **60.000**(ប្រាំមួយម៉ឺន)ដុល្លារអាមេរិក ដែលមូលប្បទានបត្រទាំងបួនសន្លឹកនេះ កំណត់ឱ្យបើកប្រាក់នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ ឱ្យទៅគ្រឹះស្ថាន **វ៉ាយ ស៊ី ភី ម៉ាយក្រូហ្វាយនែន** ម.ក ដែលមានឈ្មោះ [redacted] **សែ** ជានាយកប្រតិបត្តិការ ដើម្បីទូទាត់បំណុលដែលជំពាក់ចំនួន **70.000**(ប្រាំពីរម៉ឺន)ដុល្លារអាមេរិក ។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ ឈ្មោះ [redacted] **សែ** បានយកមូលប្បទានបត្រទាំងបួនសន្លឹកនោះទៅបើកប្រាក់នៅធនាគារ អេស៊ីលីដា ប៉ុន្តែត្រូវបានខាងធនាគារបញ្ជាក់ថា មូលប្បទានបត្រខាងលើមិនអាចទូទាត់បាន ពីព្រោះមិនមានប្រាក់ឬពុំមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ធ្វើការទូទាត់ ។

**អំពីកិច្ចពិភាក្សាដេញដោលនាពេលសវនាការ**

១- ការសួរចម្លើយជនជាប់ចោទ

- តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] លីហ៊ាង ដែលបានឆ្លើយនៅដំណាក់កាលអយ្យការ ថា កាលពីខែសីហា ឆ្នាំ២០២១ ខ្លួនពិតជាបានចេញមូលប្បទានបត្ររបស់ធនាគារ ABA ចំនួន ៤សន្លឹក ឱ្យទៅបុគ្គលិកគ្រឹះស្ថាន **វ៉ាយ ស៊ី ភី ម៉ាយក្រូហ្វាយនែន ម.ក** ខ្លួនមិនចាំលេខ ដែលមានចំនួនទឹកប្រាក់ចំនួន **20.000**(ពីរម៉ឺន)ដុល្លារអាមេរិក ពីរសន្លឹក និងទឹកប្រាក់ចំនួន **10.000**(មួយម៉ឺន)ដុល្លារអាមេរិក ពីរសន្លឹក សរុបចំនួន **60.000**(ប្រាំមួយម៉ឺន)ដុល្លារអាមេរិក ប៉ុន្តែខ្លួនមិនបានដាក់កាលបរិច្ឆេទកំណត់ឱ្យបើកប្រាក់នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ ទេ ។ លេខនេះ គឺបុគ្គលិកគ្រឹះស្ថានជាអ្នកសរសេរបន្ថែម ហើយការចេញមូលប្បទានបត្រនេះ សម្រាប់បញ្ជាក់ថា ខ្លួននៅខ្វះខាងគ្រឹះស្ថានចំនួន **60.000**(ប្រាំមួយម៉ឺន)ដុល្លារអាមេរិកទៀត ។ កន្លងមក ខ្លួនធ្លាប់ចេញមូលប្បទានបត្រឱ្យខាងគ្រឹះស្ថានឱ្យទៅបើកប្រាក់ដែរ ហើយបានកំណត់ថ្ងៃឱ្យទៅបើក ។ ប្រាក់ទាំងអស់ដែលបានខ្ចីពីគ្រឹះស្ថានមានចំនួន **70.000**(ប្រាំពីរម៉ឺន)ដុល្លារអាមេរិក អ្នកខ្ចីមានឈ្មោះ [redacted] **សារ៉** ឈ្មោះ [redacted] **ប៊ុនធា** និងឈ្មោះ [redacted] **លក្ខស៊ី** ហើយខ្លួននិងប្ដីឈ្មោះ [redacted] **ពិសិដ្ឋជាវិត** ជាអ្នកធានា ។ ក្នុងទឹកប្រាក់ចំនួន **70.000**(ប្រាំពីរម៉ឺន)ដុល្លារអាមេរិកនេះ ខ្លួនបានសង **10.000**(មួយម៉ឺន)ដុល្លារអាមេរិក ហើយ ។ ក្នុងរឿងនេះ ខ្លួនមានដំណោះស្រាយ ដោយសូមសងតាមលទ្ធភាព ក្នុងមួយខែ សូមសង **50**(ហាសិប)ដុល្លារអាមេរិក សរុបមានគ្នាបួននាក់ ស្មើនឹងទឹកប្រាក់ចំនួន **200**(ពីររយ)ដុល្លារអាមេរិក ។

- តាមអំណានសេចក្តីថ្លែងការណ៍ការពារ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] **លីហ៊ាង** និងឈ្មោះ [redacted] **ពិសិដ្ឋជាវិត** នៅដំណាក់កាលស៊ើបសួរ ថា ពួកខ្លួនបានខ្ចីប្រាក់ពីគ្រឹះស្ថាន **វ៉ាយ ស៊ី ភី ម៉ាយក្រូហ្វាយនែន ម.ក** ចំនួន **60.000**(ប្រាំមួយម៉ឺន)ដុល្លារអាមេរិក ។ ក្រោយមក ដោយសារតែជម្ងឺកូវីដរីករាលដាល ទើបធ្វើឱ្យពួកខ្លួនពុំមានលទ្ធភាពសងប្រាក់ទៅឱ្យគ្រឹះស្ថាន ។ ក្រោយមក ខាងគ្រឹះស្ថានតែងចាប់បង្ខំពួកខ្លួនឱ្យសងប្រាក់ ដោយបានឱ្យមនុស្សមកគម្រាមសម្លុតជាញឹកញាប់ រួចបន្ទាប់មក បានឈ្មោះ [redacted] **ប្រុស** និងឈ្មោះ [redacted] **តារា** ជាបុគ្គលិកគ្រឹះស្ថាន មកលួងលោមឱ្យប្រពន្ធរបស់ខ្លួនសរសេរមូលប្បទានបត្រ ដោយប្រើពាក្យថា គ្រាន់តែយកទៅតម្កល់ទុកទេ មិនបានយកទៅធ្វើអ្វីនោះទេ ។ ប្រពន្ធខ្លួនបានប្រាប់ទៅបុគ្គលិកគ្រឹះស្ថានថា មូលប្បទានបត្រនេះគ្មានសាច់ប្រាក់នោះទេ តែពួកគេនៅតែបង្ខំឱ្យប្រពន្ធខ្លួនចេញមូលប្បទានបត្រឱ្យពួកគេទៀត ទើបប្រពន្ធខ្លួនចុះហត្ថលេខាចេញមូលប្បទានបត្រ ដោយពុំមានចុះថ្ងៃខែឆ្នាំកំណត់ឱ្យបើកប្រាក់នោះទេ គឺខាងគ្រឹះស្ថានជាអ្នកចុះថ្ងៃខែឆ្នាំដោយខ្លួនឯង ។ ខ្លួននិងប្រពន្ធពុំមានចេតនាចេញមូលប្បទានបត្រអត់សាច់ប្រាក់នោះទេ ដោយសារតែបុគ្គលិករបស់គ្រឹះស្ថានបង្ខំពួកខ្លួន ទើបពួកខ្លួនចេញមូលប្បទានបត្រនោះឱ្យទៅខាងគ្រឹះស្ថាន ។ ខ្លួនសូមបញ្ជាក់ថា ខ្លួននិងប្រពន្ធបានបង់ប្រាក់ប្រចាំខែសរុបចំនួន **8.360**(ប្រាំបីពាន់បីរយហុកសិប)ដុល្លារអាមេរិក ទៅឱ្យខាងគ្រឹះស្ថានហើយ និងប្រាក់ថ្លៃរថយន្តដែលខាងគ្រឹះស្ថានបានលួចយកពីខ្លួនទៅលក់បានប្រាក់ចំនួន **18.000**(មួយម៉ឺនប្រាំបីពាន់)ដុល្លារអាមេរិក សរុបប្រាក់ដែលពួកខ្លួនបានសងមានចំនួន **26.360**(ពីរម៉ឺនប្រាំមួយពាន់បីរយហុកសិប)ដុល្លារអាមេរិក នៅខ្វះតែចំនួន **33.640**(បីម៉ឺនបីពាន់ប្រាំមួយរយសែសិប)ដុល្លារអាមេរិក ។

**២- ការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី**

- តាមអំណានចម្លើយរបស់មេធាវី [redacted] ជាមេធាវីការពារសិទ្ធិនិងតំណាងឱ្យ គ្រឹះស្ថាន **វ៉ាយ ស៊ី ភី ម៉ាយក្រូហ្វាយនែន ម.ក** ដែលបានឆ្លើយថា កាលពីអំឡុងឆ្នាំ២០១៩ បងប្អូនរបស់ឈ្មោះ **ចូវ លីហ៊ាង** បានខ្ចីប្រាក់ពីគ្រឹះស្ថាន **វ៉ាយ ស៊ី ភី ម៉ាយក្រូហ្វាយនែន ម.ក** ដែលមានឈ្មោះ [redacted] **ពិសិដ្ឋជាវិត** និងឈ្មោះ

[redacted] **លីហ៊ាង** ជាអ្នកធានា ហើយនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២០ ឈ្មោះ[redacted] **លីហ៊ាង** និងឈ្មោះ [redacted] **ពិសិដ្ឋជាវិត** បានចេញមូលប្បទានបត្រចំនួន ៤សន្លឹក របស់ **ធនាគារ វឌ្ឍនៈអាស៊ីចំកាត់**(**ABA Bank**) មានលេខ **496341** មានទឹកប្រាក់ចំនួន **20.000**(ពីរម៉ឺន)ដុល្លារអាមេរិក, លេខ **496343** មានទឹកប្រាក់ចំនួន **10.000**(មួយម៉ឺន)ដុល្លារអាមេរិក, លេខ **496342** មានទឹកប្រាក់ចំនួន **20.000**(ពីរម៉ឺន)ដុល្លារអាមេរិក និង លេខ **496344** មានទឹកប្រាក់ចំនួន **10.000**(មួយម៉ឺន)ដុល្លារអាមេរិក សរុបជាទឹកប្រាក់ចំនួន **60.000**(ប្រាំមួយម៉ឺន)ដុល្លារអាមេរិក ដែលមូលប្បទានបត្រទាំងបួនសន្លឹកនេះ កំណត់ឱ្យបើកប្រាក់នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ ឱ្យមកកូនក្តីខ្លួន ដើម្បីទូទាត់បំណុលដែលនៅជំពាក់ **70.000**(ប្រាំពីរម៉ឺន)ដុល្លារអាមេរិក ។ លុះដល់ថ្ងៃកំណត់បើកប្រាក់ កូនក្តីខ្លួនបានយកមូលប្បទានបត្រទាំងបួនសន្លឹកនោះទៅបើកប្រាក់នៅធនាគារអេស៊ីលីដា ប៉ុន្តែត្រូវបានខាងធនាគារបញ្ជាក់ថា មូលប្បទានបត្រខាងលើមិនអាចទូទាត់បាន ពីព្រោះមិនមានប្រាក់ឬពុំមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ធ្វើការទូទាត់ ។ ក្នុងរឿងនេះ កូនក្តីខ្លួនសូមប្តឹងទាមទារប្រាក់ដើមចំនួន **60.000**(ប្រាំមួយម៉ឺន)ដុល្លារអាមេរិក និងសំណងជម្ងឺចិត្តចំនួន **20.000**(ពីរមួយម៉ឺន)ដុល្លារអាមេរិក ព្រមទាំងផ្តន្ទាទោសជនប្រព្រឹត្តទៅតាមច្បាប់ ។

- លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិនិងតំណាងឱ្យគ្រឹះស្ថាន **វ៉ាយ ស៊ី ភី ម៉ាយក្រូហ្វាយ នែន ម.ក** បានឆ្លើយថា កាលបរិច្ឆេទ គឺថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ គឺជាកាលបរិច្ឆេទនៃការកំណត់ឱ្យបើកប្រាក់ សម្រាប់ទូទាត់តាមមូលប្បទានបត្រ ហើយចម្លើយនិងសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ ដែលថាការសរសេរកាលបរិច្ឆេទលើមូលប្បទានបត្រ គឺខាងគ្រឹះស្ថានជាអ្នកសរសេរនោះ គឺមិនពិតទេ ហើយខាងគ្រឹះស្ថានក៏មិនដែលបានទៅបង្ខិតបង្ខំ ឬគំរាមកំហែងលើជនជាប់ចោទដែរ ។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី

លោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ គ្រឹះស្ថាន **វ៉ាយ ស៊ី ភី ម៉ាយក្រូហ្វាយ នែន ម.ក** បានធ្វើសេចក្តីសន្និដ្ឋានការពារថា ក្រោយពីបានពិភាក្សាដេញដោលនាពេលសវនាការរួចមក ជនជាប់ចោទជាមនុស្សមានស្មារតីគ្រប់គ្រាន់ មិនមានជម្ងឺ គ្មានការបង្ខិតបង្ខំ សុខចិត្តចេញសែកធានាសម្រាប់ទូទាត់ នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ ចំនួន **60.000**(ប្រាំមួយម៉ឺន)ដុល្លារអាមេរិក ហើយខ្លួនសូមបដិសេធនូវចម្លើយនិងសេចក្តីថ្លែងការណ៍ការពាររបស់ជនជាប់ចោទ ។ សែកត្រូវតែចុះកាលបរិច្ឆេទសម្រាប់បើកក្នុងរយៈពេល៦ខែ ។ តាមអង្គហេតុនិងភស្តុតាង បានបង្ហាញថា សែកដែលជនជាប់ចោទបានចេញឱ្យមកកូនក្តីរបស់ខ្លួន គឺមិនមានប្រាក់ ឬមិនមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ទូទាត់ប្រាក់ជំពាក់កូនក្តីខ្លួនប្រាកដមែន ។ ហេតុនេះ ខ្លួនសូមសំណូមពរឱ្យតុលាការមេត្តាសម្រេចផ្តន្ទាទោសលើជនជាប់ចោទ និងឃុំខ្លួនជនជាប់ចោទ ពីបទ **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** ប្រព្រឹត្តនៅភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២៣១** នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ និងឱ្យជនជាប់ចោទសងប្រាក់ចំនួន **60.000**(ប្រាំមួយម៉ឺន)ដុល្លារអាមេរិក និងសំណងជម្ងឺចិត្តចំនួន **20.000**(ពីរម៉ឺន)ដុល្លារអាមេរិក ។

លោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ គ្រឹះស្ថាន **វ៉ាយ ស៊ី ភី ម៉ាយក្រូហ្វាយ នែន ម.ក** បានធ្វើសេចក្តីសន្និដ្ឋានការពារថា តាមអង្គហេតុនិងអង្គច្បាប់ ឃើញថាឈ្មោះ [redacted] **ពិសិដ្ឋជាវិត** និងឈ្មោះ [redacted] **លីហ៊ាង** ពិតជាបានចេញមូលប្បទានបត្រចំនួន ៤ មានលេខ



Scanned with CamScanner

**496341** លេខ **496343** លេខ **496342** និងលេខ **496344** ដែលមានទឹកប្រាក់សរុបចំនួន **60.000**( ប្រាំមួយម៉ឺន )ដុល្លារអាមេរិក សម្រាប់ទូទាត់សងបំណុលសរុប **70.000**( ប្រាំពីរម៉ឺន )ដុល្លារអាមេរិក ដែលមូលប្បទានបត្រខាងលើនេះ គឺមិនមានប្រាក់ឬមានមិនគ្រប់( Insufficient or no funds ) សម្រាប់ទូទាត់នៅថ្ងៃកំណត់ឡើយ ។ អំពើរបស់ឈ្មោះ [redacted] **ពិសិដ្ឋដារិត** និងប្រពន្ធឈ្មោះ [redacted] **លីហ៊ាង** បានធ្វើឱ្យកូនក្ដីរបស់ខ្លួន មានការខាតបង់ធ្ងន់ធ្ងរ មិនអាចទទួលបានប្រាក់ចំនួន **60.000**( ប្រាំមួយម៉ឺន )ដុល្លារអាមេរិក តាមកាលបរិច្ឆេទកំណត់សង ។ ការណ៍នេះ ជាហេតុធ្វើឱ្យប៉ះពាល់ដល់សកម្មភាពអាជីវកម្មចម្បងរបស់កូនក្ដីខ្លួន នៅក្នុងការបង្វិលសាច់ប្រាក់ក្នុងលំហូរអាជីវកម្មតាមផែនការអាជីវកម្មប្រចាំឆ្នាំដែលបានកំណត់ ខាតបង់ពេលវេលា កម្លាំងបញ្ញាស្មារតី និងចិត្តគំនិតរបស់ថ្នាក់ដឹកនាំក្រុមហ៊ុនដែលយកមកគិតគូរទៅលើការរកមធ្យោបាយដោះស្រាយចំពោះអំពើល្មើសរបស់ឈ្មោះ [redacted] **ពិសិដ្ឋដារិត** និងឈ្មោះ [redacted] **លីហ៊ាង** ។ ទង្វើប្រើឧបាយកលទុច្ចរិតរបស់ឈ្មោះ [redacted] **ពិសិដ្ឋដារិត** និងឈ្មោះ [redacted] **លីហ៊ាង** គឺធ្វើឱ្យខូចខាតនូវប្រយោជន៍របស់អតិថិជនដែលជាអ្នកខ្ចី និងធនាគារនូវទឹកប្រាក់សរុបចំនួន 70.000( ប្រាំពីរម៉ឺន )ដុល្លារអាមេរិក ផ្ដល់ផលជះដ៏អាក្រក់នៅក្នុងសកម្មភាពអាជីវកម្ម និងជំនួញក្នុងសង្គម ព្រោះបាត់ការទុកចិត្តពីពាណិជ្ជករ អាជីវករ និងសាធារណជនទូទៅ លើការប្រើឧបករណ៍ដែលអាចជួញដូរបានថែមទៀតផង ។ ហេតុនេះ ក្នុងនាមខ្លួនជាមេធាវីតំណាងឱ្យកូនក្ដី សូមសំណូមពរតុលាការផ្ដន្ទាទោសនិងឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] **ពិសិដ្ឋដារិត** និងឈ្មោះ **ចូវ លីហ៊ាង** មានទីលំនៅស្ថិតនៅភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ពីបទ **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** តាមមាត្រា **២៣១** នៃច្បាប់ស្ដីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ប្រព្រឹត្តនៅភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប និងបង្គាប់ឱ្យឈ្មោះ [redacted] **ពិសិដ្ឋដារិត** និងឈ្មោះ [redacted] **លីហ៊ាង** សងប្រាក់ចំនួន **60.000**( ប្រាំមួយម៉ឺន )ដុល្លារអាមេរិក និងសំណងជម្ងឺចិត្ត ការខាតបង់ពេលវេលា និងសេវាកម្មច្បាប់ ចំនួន **20.000**( ពីរម៉ឺន )ដុល្លារអាមេរិក មកឱ្យ **គ្រឹះស្ថាន វ៉ាយ ស៊ី ភី ម៉ាយក្រូហ្វាយនែន ម.ក** ។

## សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថា ក្រោយពីបានពិភាក្សាដេញដោលលើសំណុំរឿងព្រហ្មទណ្ឌលេខ ២៦០ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿង តំណាងអយ្យការយល់ឃើញថា ជនជាប់ចោទពិតជាបានចេញសែក ឱ្យទៅដើមបណ្ដឹងរដ្ឋប្បវេណី ហើយដើមបណ្ដឹងរដ្ឋប្បវេណីបានទៅបើកប្រាក់នៅធនាគារ ហើយខាងធនាគារបានបញ្ជាក់បញ្ជូនត្រលប់មកវិញថា គ្មានប្រាក់សម្រាប់ទូទាត់នោះទេ ។ ហេតុនេះ មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទពីបទ **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** ប្រព្រឹត្តនៅភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា **២៣១** នៃច្បាប់ស្ដីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។ ហេតុនេះ តំណាងអយ្យការសូមតម្កល់ការចោទប្រកាន់ និងសូមឱ្យតុលាការសម្រេចផ្ដន្ទាទោសជនជាប់ចោទ តាមច្បាប់ ។

- **ក្រោយពី** បានស្ដាប់អំណានចម្លើយរបស់ជនជាប់ចោទ
- **ក្រោយពី** បានស្ដាប់អំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី
- **ក្រោយពី** បានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី
- **ក្រោយពី** បានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ
- **ក្រោយពី** បានពិនិត្យលើកស្ដូតាងឯកសារផ្សេងៗក្នុងសំណុំរឿង



Scanned with CamScanner

## ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ
## សំអាងហេតុ

១- សាលាដំបូងខេត្តសៀមរាបបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ **២៦០** ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទឈ្មោះ [redacted] **លីហ៊ាង** ភេទស្រី អាយុ៥៧ឆ្នាំ និងឈ្មោះ [redacted] **ពិសិដ្ឋដាវិត** ភេទប្រុស អាយុ៥៥ឆ្នាំ ដែលត្រូវបានបញ្ជូនមកជំនុំជម្រះ ពីបទ **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** ប្រព្រឹត្តនៅភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២៣១** នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។ តាមដីកាដំណោះស្រាយលេខ **៥១៧៥ ពស.ព្រស/ឱ** ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប និងតាមមាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នាំឱ្យសាលាដំបូងខេត្តសៀមរាប មានសមត្ថកិច្ចក្នុងការជំនុំជម្រះ ។

២- តាមដីកាដំណោះស្រាយលេខ **៥១៧៥ ពស.ព្រស/ឱ** ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប ដែនកំណត់នៃការប្តឹងមកតុលាការចំពោះអង្គហេតុ តាមមាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងដែនកំណត់នៃការប្តឹងមកតុលាការចំពោះបុគ្គល តាមមាត្រា ៣៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នាំឱ្យសាលាដំបូងខេត្តសៀមរាបមានសមត្ថកិច្ច ក្នុងការជំនុំជម្រះលើអង្គហេតុដែលប្តឹងមកតុលាការ និងចំពោះជនជាប់ចោទឈ្មោះ [redacted] **លីហ៊ាង** ភេទស្រី អាយុ៥៧ឆ្នាំ និងឈ្មោះ [redacted] **ពិសិដ្ឋដាវិត** ភេទប្រុស អាយុ៥៥ឆ្នាំ ដូចមានអត្តសញ្ញាណខាងលើ ។

៣- តាមពាក្យបណ្តឹង ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ និងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ថា នៅថ្ងៃទី២១ វិច្ឆិកា ឆ្នាំ២០២២ ជនជាប់ចោទឈ្មោះ [redacted] **ពិសិដ្ឋដាវិត** និងឈ្មោះ [redacted] **លីហ៊ាង** បានចេញមូលប្បទានបត្រ ចំនួន ៤សន្លឹក របស់ **ធនាគារ វឌ្ឍនៈអាស៊ីចំកាត់(ABA Bank)** មានលេខ **496341** មានទឹកប្រាក់ចំនួន **20.000**(ពីរម៉ឺន)ដុល្លារអាមេរិក, លេខ **496343** មានទឹកប្រាក់ចំនួន **10.000**(មួយម៉ឺន)ដុល្លារអាមេរិក, លេខ **496342** មានទឹកប្រាក់ចំនួន **20.000**(ពីរម៉ឺន)ដុល្លារអាមេរិក និងលេខ **496344** មានទឹកប្រាក់ចំនួន **10.000**(មួយម៉ឺន)ដុល្លារអាមេរិក សរុបជាទឹកប្រាក់ចំនួន **60.000**(ប្រាំមួយម៉ឺន)ដុល្លារអាមេរិក ដើម្បីទូទាត់បំណុលដែលជំពាក់ចំនួន **70.000**(ប្រាំពីរម៉ឺន)ដុល្លារអាមេរិក ហើយមូលប្បទានបត្រទាំងបួនសន្លឹកនេះ ក៏បានថ្ងៃកំណត់ឱ្យបើកប្រាក់ ។ លុះនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ ដើមបណ្តឹងរដ្ឋប្បវេណីបានយកមូលប្បទានបត្រទាំងបួនសន្លឹកនោះទៅបើកប្រាក់នៅធនាគារ អេស៊ីលីដា ប៉ុន្តែត្រូវបានធនាគារបញ្ជាក់ថា មូលប្បទានបត្រខាងលើ មិនអាចទូទាត់បាន ពីព្រោះមិនមានប្រាក់ឬពុំមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ធ្វើការទូទាត់ ។ ចម្លើយនេះមានភាពសមស្របនឹងចម្លើយនិងសេចក្តីថ្លែងការណ៍ការពាររបស់ជនជាប់ចោទដែលបានឆ្លើយទទួលស្គាល់ថា ពួកខ្លួនពិតជាបានចេញមូលប្បទានបត្រទាំងបួនសន្លឹកនេះប្រាកដមែន ។

៤- តាមមូលប្បទានប័ត្របញ្ជូនត្រលប់ (NOTICE OF RETURNED CHECK) ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ លើមូលប្បទានបត្រលេខ **496341** និងលេខ **496343** និងមូលប្បទានប័ត្របញ្ជូនត្រលប់ (NOTICE OF RETURNED CHECK) ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ លើមូលប្បទានបត្រលេខ **496342** និងលេខ **496344** ដែលមានធនាគារ វឌ្ឍនៈអាស៊ីចំកាត់(ABA Bank) ជាបង្ហាគិត និងឈ្មោះ [redacted] **ពិសិដ្ឋដាវិត [LONG PISITHDAVID]** និងឈ្មោះ [redacted] **លីហ៊ាង [CHOV LIHEANG]** ជា បង្ហាក់ បាន



Scanned with CamScanner

បង្ហាញនិងបញ្ជាក់ឱ្យឃើញថា មិនមានប្រាក់ ឬពុំមានសាច់ប្រាក់គ្រប់គ្រាន់ [Insufficient or no funds] ។

៥- ចម្លើយរបស់ជនជាប់ចោទ និងចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី មានសង្គតិភាពជាមួយមូលប្បទានប័ត្របញ្ជូនត្រលប់ (NOTICE OF RETURNED CHECK) ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ លើមូលប្បទានបត្រលេខ **496341** និងលេខ **496343** និងមូលប្បទានប័ត្របញ្ជូនត្រលប់ (NOTICE OF RETURNED CHECK) ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ លើមូលប្បទានបត្រលេខ **496342** និងលេខ **496344** និងភស្តុតាងទាំងឡាយក្នុងសំណុំរឿង ដែលបានបង្ហាញឱ្យឃើញថាអំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ពិសិដ្ឋដារិត** និងឈ្មោះ [redacted] **លីហ៊ាង** ដែលបានចេញមូលប្បទានបត្រឱ្យទៅដើមបណ្ដឹងរដ្ឋប្បវេណី ហើយនាពេលត្រូវទូទាត់សងនោះ មូលប្បទានបត្រទាំងនោះមិនមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ទូទាត់សង បានឆ្លើយតបនឹងធាតុផ្សំនៃបទល្មើស **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** ប្រព្រឹត្តនៅភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា **២៣១** នៃច្បាប់ស្ដីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

៦- ចម្លើយរបស់ជនជាប់ចោទ ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងភស្តុតាងក្នុងសំណុំរឿង មានភាពស៊ីសង្វាក់គ្នាគ្រប់គ្រាន់ដែលបង្ហាញឱ្យឃើញថា ឈ្មោះ[redacted] **ពិសិដ្ឋដារិត** និងឈ្មោះ [redacted] **លីហ៊ាង** ពិតជាមានចេតនា ក្នុងការបង្កឱ្យមានបទល្មើសកើតឡើង ដែលពិតជាបានប៉ះពាល់ដល់សុវត្ថិភាព ស្ថិរភាពពាណិជ្ជកម្ម សិទ្ធិ និងផលប្រយោជន៍អ្នកដទៃ និងសណ្ដាប់ធ្នាប់សាធារណៈ ដែលត្រូវជានាការពារដោយច្បាប់ជាធរមាន ។ម្យ៉ាងវិញទៀត មិនមានភស្តុតាងណាមួយបង្ហាញជនជាប់ចោទទាំងពីរ មិនមានភាពយល់ដឹងនិងមិនអាចវិនិច្ឆ័យបាននូវអំពើនិងបច្ច័យនៃអំពើរបស់ពួកខ្លួននោះទេ និងហេតុដូច្នេះជនជាប់ចោទទាំងពីរត្រូវទទួលខុសត្រូវនូវការប្រព្រឹត្តរបស់ពួកខ្លួន ។

**៧**- មានភស្តុតាងលើសពីវិមតិសង្ស័យ និងធាតុផ្សំបទល្មើសគ្រប់គ្រាន់ បង្ហាញថាជនជាប់ចោទឈ្មោះ [redacted] **ពិសិដ្ឋដារិត** និងឈ្មោះ [redacted] **លីហ៊ាង** (មានអត្តសញ្ញាណដូចខាងលើ) មានពិរុទ្ធភាពពីបទ **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** ប្រព្រឹត្តនៅភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា **២៣១** នៃច្បាប់ស្ដីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

៨- មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី បានធ្វើសេចក្ដីសន្និដ្ឋានជាគោលថាតាមអង្គហេតុ អង្គច្បាប់ និងភស្តុតាង បានបង្ហាញថា មូលប្បទានបត្រដែលជនជាប់ចោទបានចេញឱ្យមកកូនក្ដីរបស់ខ្លួន គឺមិនមានប្រាក់ ឬមិនមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ទូទាត់ប្រាក់ជំពាក់កូនក្ដីខ្លួនប្រាកដែន ។ ហេតុនេះខ្លួនសូមសំណូមពរឱ្យតុលាការមេត្តាសម្រេចផ្ដន្ទាទោសលើជនជាប់ចោទ និងឃុំខ្លួនជនជាប់ចោទពីបទ **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** ។ ***ឃើញថា*** សេចក្ដីសន្និដ្ឋានការពារនេះ មានមូលដ្ឋានសមហេតុសមផល ដែលតុលាការអាចពិនិត្យ និងពិចារណាបាន ។

៩- តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំជាគោលថា ពិតជាមានការចេញសែក ហើយក៏មានការបញ្ជាក់បញ្ជូនត្រលប់មកវិញថា គ្មានប្រាក់សម្រាប់ទូទាត់នោះទេ ។ ហេតុនេះ មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទពីបទ **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** ហេតុនេះ តំណាងអយ្យការសូមតម្កល់ការចោទប្រកាន់ និងសូមឱ្យតុលាការសម្រេចផ្ដន្ទាទោសជនជាប់ចោទ តាមច្បាប់ ។ ***ឃើញថា***



Scanned with CamScanner

សេចក្ដីសន្និដ្ឋានប្ដឹងសុំនេះ មានហេតុផលត្រឹមត្រូវ ដែលតុលាការអាចយកមកពិនិត្យ និងពិចារណា ព្រមទាំងសម្រេចតាមច្បាប់ ។

១០- ជនជាប់ចោទឈ្មោះ [redacted] **ពិសិដ្ឋដារិត** និងឈ្មោះ [redacted] **លីហ៊ាង** មិនមានប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការពីមុន ប៉ុន្តែបានព្យាយាមឆ្លើយគេចវេះពីការទទួលខុសត្រូវរបស់ខ្លួន គេចវេះពីនីតិវិធីតុលាការកន្លងមក ហើយអំពើរបស់ ជនជាប់ចោទបានប៉ះពាល់ដល់សិទ្ធិ ទំនុកចិត្ត ផលប្រយោជន៍ដើមបណ្ដឹងរដ្ឋប្បវេណីនិងស្ថិរភាពជំនួញ ។ តាមបុគ្គលិកលក្ខណៈ ស្ថានភាពនៃបទល្មើស និងទំហំនៃព្យសនកម្ម តុលាការគប្បីពិនិត្យ ពិចារណា និងសម្រេចផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **ពិសិដ្ឋដារិត** និងឈ្មោះ [redacted] **លីហ៊ាង** ដោយប្រកាសទោសក្នុងកម្រិតកំណត់ ១(មួយ)ឆ្នាំ ដែលជាទោសជួនល្មមតាមច្បាប់ ពីបទ **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** តាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្ដីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់សងប្រាក់ និងគប្បីសម្រេចឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ[redacted] **លីហ៊ាង** មកអនុវត្តការផ្ដន្ទាទោស តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

១១- ភាគីដើមបណ្ដឹងរដ្ឋប្បវេណី បានទាមទារឱ្យជនជាប់ចោទសងប្រាក់ចំនួន 60.000(ប្រាំមួយម៉ឺន) ដុល្លារអាមេរិក និងសំណងជម្ងឺចិត្ត ការខាតបង់ពេលវេលានិងសេវាកម្មច្បាប់ ចំនួន 20.000(ពីរមួយម៉ឺន) ដុល្លារអាមេរិក ។ ***ឃើញថា*** ដើមបណ្ដឹងរដ្ឋប្បវេណី និងជនជាប់ចោទបានបង្កើតទំនាក់ទំនងកាតព្វកិច្ចដែលមានគោលបំណងឱ្យសងជាប្រាក់ជាមួយគ្នា ហើយតាមមូលប្បទានបត្រចំនួន ៤សន្លឹក ដែលជនជាប់ចោទបានចេញសម្រាប់ជាមធ្យោបាយនៃការទូទាត់ មានទឹកប្រាក់សុរប 60.000(ប្រាំមួយម៉ឺន)ដុល្លារអាមេរិក ។ ហេតុនេះ ការទាមទារសំណងការខូចខាតចំនួន 60.000(ប្រាំមួយម៉ឺន)ដុល្លារអាមេរិក ក្នុងទំនាក់ទំនងបទល្មើសនេះ មានហេតុផលត្រឹមត្រូវ ដែលតុលាការគប្បីពិនិត្យនិងសម្រេចអំពីសំណងការខូចខាតនេះក្នុងចំនួន 60.000(ប្រាំមួយម៉ឺន)ដុល្លារអាមេរិក នេះ ។ លើសពីនេះទៀត ដើមបណ្ដឹងរដ្ឋប្បវេណីបានទាមទារសំណងជម្ងឺចិត្តការខាតបង់ពេលវេលា និងសេវាកម្មច្បាប់ ចំនួន 20.000(ពីរមួយម៉ឺន)ដុល្លារអាមេរិក ។ ***ឃើញថា*** ក្នុងគោលការណ៍នៃការគណនាចំនួនទឹកប្រាក់នៃការខូចខាត និងសំណងជម្ងឺចិត្ត តាមមូលដ្ឋានច្បាប់ជាធរមាន ផ្អែកតាមស្ថានភាពនៃទ្រព្យសម្បត្តិជាប្រាក់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវបានសន្មតថានឹងមានប្រសិនបើគ្មានអំពើល្មើសរបស់ជនជាប់ចោទ និងស្ថានភាពនៃទ្រព្យសម្បត្តិជាប្រាក់ជាក់ស្ដែង ក្រោយពេលដែលអំពើល្មើសបានកើតឡើង ហេតុនេះតុលាការគប្បីពិនិត្យ ពិចារណា និងសម្រេចលើការទាមទារសំណងការខូចខាត និងសំណងជម្ងឺចិត្តនេះ ដោយផ្អែកលើការវាយតម្លៃ ខាងលើកម្រិតនៃកំហុស កម្រិតនៃការរងគ្រោះអំពើរបស់អ្នកប្រព្រឹត្តអំពើបំពាន នៅក្រោយអំពើបង្កឱ្យមានការរងគ្រោះ និងភាពជួនល្មមនឹងព្យសនកម្មដែលទទួលរងនេះ ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងការទាមទារនេះ ភាគីដើមបណ្ដឹងរដ្ឋប្បវេណីមិនបានបង្ហាញនូវទំហំនៃការខូចខាតជាក់ស្ដែងនិងច្បាស់លាស់ ដែលអាចយកមកធ្វើជាមូលដ្ឋាននៃការសម្រេចអំពីសំណងដែលសមស្របនឹងការខូចខាតឡើយ ។ម្យ៉ាងវិញទៀត ការចំណាយលើសេវាកម្មផ្លូវច្បាប់ គឺជាការអនុវត្តសិទ្ធិការពារខ្លួនរបស់គូភាគីតាមផ្លូវច្បាប់ ដែលជាទូទៅ បន្ទុកនេះជារបស់គូភាគីតាមផ្លូវច្បាប់ ។ ហេតុនេះ តុលាការគប្បីពិនិត្យ ពិចារណា និងសម្រេចច្រានចោលនូវការទាមទារនេះ ។

## ហេតុដូច្នេះ សម្រេច

១- ផ្ដន្ទាទោសជនជាប់ចោទឈ្មោះ[redacted] **លីហ៊ាង** ភេទស្រី អាយុ៥៧ឆ្នាំ មានអត្តសញ្ញាណដូចខាងលើ (គេចខ្លួន) ដាក់ពន្ធនាគារកំណត់ **១(មួយ)ឆ្នាំ**



Scanned with CamScanner

ពីបទ **មិនបំពេញភាពកតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** ប្រព្រឹត្តនៅភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២៣១** នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

២- ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **ពិសិដ្ឋជាទិត** ភេទប្រុស អាយុ៥៥ឆ្នាំ មានអត្តសញ្ញាណដូចខាងលើ (គេចខ្លួន) ដាក់ពន្ធនាគារកំណត់ **១(មួយ)ឆ្នាំ**

ពីបទ **មិនបំពេញភាពកតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** ប្រព្រឹត្តនៅភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២៣១** នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

៣- ឱ្យឈ្មោះ [redacted] **លីហ៊ាន** និងឈ្មោះ [redacted] **ពិសិដ្ឋជាទិត** សងសំណងការខូចខាតនិងជម្ងឺចិត្តចំនួន **USD 60.000**( ប្រាំមួយម៉ឺន )ដុល្លារអាមេរិក ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណី ។ ច្រានចោលការទាមទារលើសពីនេះ ។

៤- បង្គាប់ឱ្យចាប់ខ្លួនពិរុទ្ធជនឈ្មោះ [redacted] **លីហ៊ាន** មានអត្តសញ្ញាណដូចខាងលើ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤ កំបាំងមុខជនជាប់ចោទ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៤ ។

**ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។**

**ក្រឡាបញ្ជី**
ហត្ថលេខា និងត្រា
[redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា
[redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ថ្ងៃព្រហស្បតិ៍ ១៤រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
ខេត្តសៀមរាប ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៤
**ក្រឡាបញ្ជី**
[redacted]

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**
[redacted]